# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខៈ ០៤៧ MIH / 2016

## ប្រកាស
## ស្តីពី
## ការកែសម្រួលការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួង ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ១ ៖** ត្រូវបានកែសម្រួលការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួង ទទួលបន្ទុកតាមដានការងារនៅតាមមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត ដូចខាងក្រោម ៖

១- ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម ទទួលដឹកនាំរួមរាល់កិច្ចការដែលពាក់ព័ន្ធនឹងរដ្ឋបាលថ្នាក់ក្រោមជាតិ និងទទួលផ្ទាល់ការពិនិត្យមើលការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ខេត្តកំពត ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តព្រះសីហនុ ខេត្តស្ទឹងត្រែង និងខេត្តកែប។

២- ឯកឧត្តម **សាត សាមី** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម
សង្កាត់ផ្សារថ្មី ៣ ខណ្ឌដូនពេញ
ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តម ទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
ទូរសារលេខ: (៨៥៥) ២៣២១១ ៨៥៥
អ៊ីមែល: mih.smcabinet@gmail.com

៣- ឯកឧត្តម **ភោគ សុវណ្ណរិទ្ធ** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ និងខេត្តកោះកុង។

៤- ឯកឧត្តម **ឯក សុនចាន់** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម រាជធានីភ្នំពេញ ខេត្តសៀមរាប និងខេត្តតាកែវ។

៥- ឯកឧត្តម **ហេង សុខគង់** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តបន្ទាយមានជ័យ ខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

៦- លោកជំទាវ **ឡាយ ណាវីន** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង។

៧- ឯកឧត្តម **គីម ទូច** រដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តកំពង់ធំ ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។

៨- ឯកឧត្តម **ទឹង ស៊ីនី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្មខេត្តកំពង់ឆ្នាំង និងខេត្តកោះកុង។

៩- ឯកឧត្តម **កែ គី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តបាត់ដំបង ខេត្តព្រះវិហារ និងខេត្តតាកែវ។

១០- លោកជំទាវ **ឃុន វ៉ារី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តកំពង់ធំ។

១១- ឯកឧត្តម **សយ គីរម្យ** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តព្រៃវែង ខេត្តពោធិ៍សាត់ និងខេត្តស្វាយរៀង។

១២- ឯកឧត្តម **អ៊ុច បូរ៉ា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តឧត្តរមានជ័យ។

១៣- ឯកឧត្តម **លឹម គង់** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តបន្ទាយមានជ័យ និងខេត្តត្បូងឃ្មុំ។

១៤- ឯកឧត្តម **មាន សុភា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តស្ទឹងត្រែង និងខេត្តកែប។

១៥- ឯកឧត្តម **ជួន វន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្ម ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តសៀមរាប និងខេត្តប៉ៃលិន។

១៦- ឯកឧត្តម **សុន សេងហ្វត** អនុរដ្ឋលេខាធិការ ទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និង សិប្បកម្មខេត្តកំពត ខេត្តកណ្ដាល រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ។

**ប្រការ២ ៖** ថ្នាក់ដឹកនាំទទួលបន្ទុកតាមដានការងារមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត មានភារកិច្ចជួយសម្របសម្រួល និងពិនិត្យដោះស្រាយសំណូមពរការងារ ឬការលំបាកផ្សេងៗរបស់មន្ទីរ ក្នុងក្របខណ្ឌសមត្ថកិច្ចដែលខ្លួនទទួលខុសត្រូវ ឬអាចលើកយោបល់ជូនថ្នាក់ដឹកនាំក្រសួងដែលទទួលបន្ទុកតាមវិស័យការងារ ដើម្បីជួយសម្រួលដោះស្រាយ ឬ/និងស្នើសុំមតិរដ្ឋមន្ត្រីពិនិត្យ សម្រេច។

**ប្រការ៣ ៖** ថ្នាក់ដឹកនាំក្រសួង អាចចាត់មន្ត្រីតាមនាយកដ្ឋាន អគ្គនាយកដ្ឋាន ឬអង្គភាពថ្នាក់ស្មើអគ្គនាយកដ្ឋាន ដែលស្ថិតក្រោមបន្ទុកទទួលខុសត្រូវរបស់ខ្លួន ចូលរួមជួយការងារថ្នាក់ដឹកនាំក្រសួង ដើម្បីចុះបំពេញភារកិច្ចនៅតាមមន្ទីរគោលដៅ ទៅតាមសំណូមពរការងារចាំបាច់ និងពេលវេលាតម្រូវជាក់ស្តែង។

**ប្រការ៤ ៖** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥ ៖** នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានវិទ្យាស្ថាន ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួង ប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត និងសមាសភាពដូចមានឈ្មោះ ក្នុងប្រការ១ ត្រូវអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

**ចម ប្រសិទ្ធ**

<u>កន្លែងទទួល</u> ៖
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- សាលារាជធានី ខេត្ត

  *«ដើម្បីជូនជ្រាប»*
- ដូចប្រការ៥ *«ដើម្បីអនុវត្ត»*
- ឯកសារ-កាលប្បវត្តិ